ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០០៦៦ សជណ.កសក

# សេចក្តីជូនដំណឹង
# ស្តីពី
# ការការពារ និង ទប់ស្កាត់ភ្លើងឆេះព្រៃ

ជាធម្មតា ភ្លើងឆេះព្រៃងាយកើតមានឡើងក្នុងរដូវប្រាំងចាប់ពីខែ ធ្នូ ដល់ ខែ មេសា ជារៀងរាល់ឆ្នាំ ហើយអានុភាពភ្លើងឆេះព្រៃបង្កឡើងខ្លាំងក្លានៅឆ្នាំណាដែលមានភាពរាំងស្ងួតខ្លាំង ជាពិសេសនៅតាមតំបន់ព្រៃល្បោះដើមឈើទាំងឡាយបានចាប់ផ្តើមធ្វើការជំរុះស្លឹកមកលើផ្ទៃដី គួបផ្សំនឹងកំរាលស្មៅងាប់បង្កើតបានជាស្រទាប់មួយ ងាយឆេះបំផុត បើសិនជាមានភ្លើង ។

ភ្លើងឆេះព្រៃ អាចកើតមានដោយសារបាតុភូតធម្មជាតិ ឬ ដោយសារការដុតដោយមនុស្សផ្ទាល់ ។ កត្តាចំបងដែលបង្កឱ្យភ្លើងឆេះព្រៃញឹកញាប់ជាងគេនៅព្រះរាជាណាចក្រកម្ពុជានោះ គឺតាមរយៈសកម្មភាពរបស់មនុស្សដូចជា : ការដុតព្រៃឈើដើម្បីចាប់សត្វធ្វើជាអាហារ ការកាប់ដុតរានព្រៃឈើដើម្បីអភិវឌ្ឍន៍ការងារកសិកម្ម ការកាប់ដុតព្រៃឈើ ដើម្បីតាំងទីលំនៅថ្មី ។ល។

ឆ្លងតាមរយៈសកម្មភាពខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទសង្កេតឃើញជាញឹកញាប់ថា ភ្លើងឆេះព្រៃបានបង្កផលវិបាកធ្ងន់ធ្ងរជាច្រើនដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ សេដ្ឋកិច្ចជាតិ និង បរិស្ថានធម្មជាតិ ដោយភ្លើងបានឆាបឆេះរាលដាល :

-បំផ្លាញទ្រព្យសម្បត្តិ ផលដំណាំ និង អាយុជីវិតរបស់ប្រជាពលរដ្ឋ

-ធ្វើឱ្យបាត់បង់ និង បំផ្លិចបំផ្លាញជំរក និង អាយុជីវិតនៃពពួកសត្វព្រៃគ្រប់ប្រភេទដែលរស់នៅក្នុងព្រៃនោះ

-បំផ្លាញប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ និង តំបន់ព្រៃឈើដ៏ល្អប្រណីតដែលជា សក្តានុពលរបស់ធម្មជាតិ ។

ស្ថិតក្នុងស្ថានភាពបែបនេះ ដើម្បីរួមចំណែកការពារព្រៃឈើ និង សត្វព្រៃ ទប់ទល់នឹងភ្លើងឆេះព្រៃ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់ព្រៃឈើ ឬធ្វើដំណើរឆ្លងកាត់តំបន់ព្រៃឈើ សូមមានការប្រុងប្រយ័ត្ន និងមានវិធានការដូចខាងក្រោម :

- ចៀសវាងបោះកន្ទុយបារីដែលពុំទាន់បានពន្លត់ ឬបង្កភ្លើងផ្សេងទៀតតាមជាយព្រៃ ឬក្នុងព្រៃ
- ពេលដណ្តាំបាយក្នុងព្រៃ ត្រូវពន្លត់ភ្លើងកន្ទុយអុសឱ្យអស់សិន មុននឹងចេញដំណើរបន្តទៀត
- ហាមប្រើភ្លើងជាមធ្យោបាយរុករកឃ្មុំ ឬ ចាប់សត្វព្រៃផ្សេងទៀតនៅក្នុងព្រៃ
- ហាមដុតស្មៅក្នុងព្រៃ ដើម្បីយកល្បាស់ធ្វើជាចំណីសត្វ
- ហាមដុតព្រៃសំរាប់ធ្វើចំការ-ចំការពនេចរ
- ហាមដុតព្រៃក្នុងគោលបំណងសំអាតទីធ្លាសំរាប់សង់លំនៅដ្ឋានថ្មី
- ត្រូវពន្លត់ភ្លើងឱ្យអស់ជាចាំបាច់ មុននឹងចេញពីដើមច្បោះជ័រ (ឈើរណ្តៅជ័រ) ។

នៅពេលកើតមានភ្លើងឆេះព្រៃ ត្រូវជូនដំណឹងជាប្រញាប់ដល់អង្គភាពរដ្ឋបាលព្រៃឈើ ឬ រដ្ឋអំណាចមូលដ្ឋានដែលនៅជិតបំផុត ។ ករណីនេះមូលដ្ឋាននីមួយៗត្រូវចេះប្រើកំលាំងសរុបរួមមាន ប្រជាពលរដ្ឋ សិស្ស ព្រះសង្ឃ អង្គភាពយោធា និង នគរបាលដែលឈរជើងនៅទីនោះ ដើម្បីរួមគ្នាពន្លត់ភ្លើងព្រៃឱ្យមាន ប្រសិទ្ធភាព ។

អនុលោមតាមច្បាប់ស្តីពីព្រៃឈើជាធរមាន ប្រជាពលរដ្ឋ កងកំលាំងប្រដាប់អាវុធ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវមានករណីយកិច្ចទទួលខុសត្រូវ ថែរក្សា ការពារព្រៃឈើ បង្ការ និង ប្រយុទ្ធនឹងភ្លើងឆេះព្រៃនៅតាមមូលដ្ឋានរៀងៗខ្លួន ស្របតាមមាត្រា ៣៦ ។ ការប្រព្រឹត្ត ឬ បង្កឱ្យមានភ្លើងឆេះព្រៃ គឺជាបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៩៧ ដោយត្រូវជាប់ពន្ធនាគារពី ៥ ទៅ ១០ឆ្នាំ ។

រដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ មានភារកិច្ចផ្ទាល់ក្នុងការដឹកនាំចលនាទប់ស្កាត់ប្រយុទ្ធនឹងភ្លើងឆេះព្រៃនៅមូលដ្ឋានរបស់ខ្លួនដោយសហការជិតស្និទ្ធជាមួយអាជ្ញាធរដែនដី និង ត្រូវចាត់ចែងផ្សព្វផ្សាយនៅតាមមូលដ្ឋានរបស់ខ្លួនព្រមទាំងបិទពាក្យស្លោក ឬរូបសញ្ញា ដែលមានអត្ថន័យក្នុងការការពារ ទប់ស្កាត់ភ្លើងឆេះព្រៃនៅតាមតំបន់ដែលមានប្រជាពលរដ្ឋចេញ ចូលច្រើនជាពិសេសនៅតាមតំបន់ដែលងាយទទួលគ្រោះថ្នាក់ ដោយភ្លើងឆេះព្រៃ ។

ទទួលបានសេចក្តីជូនដំណឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សង្ឃឹមយ៉ាងមុតមាំថា គ្រប់ស្ថាប័នដែលមានការពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង ប្រជាពលរដ្ឋនឹង

ចូលរួមសហការបានល្អជាមួយសមត្ថកិច្ចរដ្ឋបាលព្រៃឈើ តាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ដើម្បីធានាការពារនិងទប់ស្កាត់ភ្លើងឆេះព្រៃឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ខែ មករា ឆ្នាំ ២០០៥

**រដ្ឋមន្ត្រី**

ចាន់ សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួង សេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងបរិស្ថាន
- ក្រសួងធនធានទឹក និង ឧតុនិយម
- ក្រុមប្រឹក្សាស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- អង្គភាពពាក់ពន្ធ័ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ